ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 01 / 2013
ម៉ោង (Time/Heure): 15:05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/152

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ១២ ខែ ធ្នូ ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៣៩

រៀបចំដោយ: ដាវ អានសាន និង Matteo CRIPPA

| <u>កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ</u> |
| --- |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក Matteo CRIPPA, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក ចាន់ តារារស្មី, លោក Dale LYSAK, លោក Vincent DE WILDE D'ESTMAEL |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន, អៀង សារី (ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI, លោក Jasper PAUW |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ អង្គ, លោក សំ សុគង់, លោកស្រី Christine MARTINEAU, លោក Emmanuel JACOMY, លោកស្រី Isabelle DURAND, លោកស្រី ស៊ិន សូវន, លោក វ៉ែន ពៅ |
| សាក្សី៖ លោក ខាំ ផាន់ ហៅ ផាន វ៉ាន (TCW-307) (លោក ម៉ម ឫទ្ធា ជាមេធាវីអម)<br>ដើមបណ្ដឹងរដ្ឋប្បវេណី៖ AFFONCO Denise (TCCP-01) ដែលមានវត្តមានមេធាវីអម Julien RIVET |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា Eleanor DOYLE-MARKWICK |

| <u>ពេលវេលាទូទៅរបស់តុលាការ៖</u> | | |
|---|---|---|
| ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.៣៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ មិនមាន | បញ្ចប់ម៉ោង៖ មិនមាន |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៥០ | បញ្ចប់ម៉ោង៖ ១៤.១០ |
| សម្រាកពេលល្ងាច | ចាប់ផ្ដើមម៉ោង៖ មិនមាន | បញ្ចប់ម៉ោង៖ មិនមាន |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៥ ម៉ោង និង ១០ នាទី | | |

<u>**កិច្ចដំណើរការនីតិវិធី៖**</u>

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| បញ្ហាបច្ចេកទេសសំឡេង | | ៩.០៥ | ៩.១៤ |
| សំណើសុំបន្ថែមពេលវេលា | សហព្រះរាជអាជ្ញា<br>មេធាវី អៀង សារី<br>មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>មេធាវី នួន ជា | ០៩.១៤ | ០៩.២៧ |
| ការបន្តស្ដាប់សក្ខីកម្មរបស់សាក្សី ផាន វ៉ាន ហៅ ខាំ ផាន់ (TCW-307) | សហព្រះរាជអាជ្ញា<br>មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី | ០៩.២៧<br>១០.៣២ | ១០.២៩<br>១១.២៨ |

| | | | |
|---|---|---|---|
| | អង្គជំនុំជម្រះ | ១១.២៨ | ១១.៤៥ |
| ការជំទាស់ចំពោះសំណួររបស់ចៅក្រម | មេធាវី នួន ជា | ១១.៣៩ | ១១.៤៥ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | ជនជាប់ចោទ នួន ជា | ១១.៤៨ | ១១.៤៩ |
| ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី AFFONCO Denise (TCCP-01) | អង្គជំនុំជម្រះ<br>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា | ១៤.១១<br>១៤.២៥<br>១៥.៥៧ | ១៤.១៩<br>១៥.៥៦<br>១៦.៣០ |
| សំណើទទួលស្គាល់មេធាវីអន្តរជាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១៤.១៩ | ១៤.២៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>សំណើសុំបន្ថែមពេលវេលាសួរសំណួររបស់សហព្រះរាជអាជ្ញា</u>**

សហព្រះរាជអាជ្ញាស្នើសុំបន្ថែមពេលវេលា ១៥នាទី ពោលគឺរហូតដល់ម៉ោង ១១.៣០នាទី ដោយលើកឡើងអំពីការបាត់ពេលវេលារបស់ខ្លួននៅពេលអង្គជំនុំជម្រះប្រកាសសេចក្តីសម្រេចផ្ទាល់មាត់។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រសំណើ។ មេធាវី អៀង សារី ជំទាស់សំណើ។ មេធាវី នួន ជា គាំទ្រសំណើ លុះណាតែក្រុម នួន ជា នឹងត្រូវបានផ្តល់ឱកាសដូច្នេះដូចគ្នាដែរ។ អង្គជំនុំជម្រះសម្រេចពិនិត្យពិចារណាតាមការជាក់ស្តែងនៃដំណើរការតាំងសំណួរដោយផ្អែកលើភាពជាប់ពាក់ព័ន្ធ។

**<u>ការបន្តស្តាប់សក្ខីកម្មរបស់សាក្សី ផាន ផាន ហៅ ខាំ ផាន់ (TCW-307)</u>**

សហព្រះរាជអាជ្ញាបន្តការតាំងសំណួរដល់សាក្សី បន្តដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចៅក្រមនៃអង្គជំនុំជម្រះ អស់រយៈពេលវេលាដែលមាននៅពេលព្រឹកនៃដំណើរការសវនាការ។

**<u>ការជំទាស់ចំពោះសំណួររបស់ចៅក្រម</u>**

ក្រុមមេធាវីការពារក្តី នួន ជា ជំទាស់នឹងសំណួរដោយចៅក្រម Lavergne ចំពោះសាក្សី។ អង្គជំនុំជម្រះប្រាប់ដល់ភាគីនៅក្នុងសវនាការថា ភាគីមិនអាចជំទាស់ទៅនឹងសំណួររបស់ចៅក្រមបានឡើយ។

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់</u>**

ជនជាប់ចោទ នួនជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់

សម្រាប់ពេលរសៀល។ អង្គជំនុំជម្រះយល់ព្រមតាមការស្នើសុំ ។

**ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-1 (តាមរយៈសោតទស្សន៍)**

អង្គជំនុំជម្រះបានចាប់ផ្តើមតាំងសំណួរបឋមទៅដើមបណ្តឹងរដ្ឋប្បវេណី ដែលផ្តល់សក្ខីកម្មតាមរយៈសោតទស្សន៍ពីប្រទេសបារាំង។ ជាបន្តបន្ទាប់ មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី, សហព្រះរាជអាជ្ញា បានតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់វេលាសវនាការពេលមួយរសៀល។

**សំណើទទួលស្គាល់មេធាវីអន្តរជាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះទទួលលោកមេធាវី Julien RIVET ដែលជាមេធាវីអមដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះបានសម្រេចថា ដោយមេធាវីរូបនេះ មិនសួរសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងមិនមានវត្តមាននៅក្នុងបន្ទប់សវនាការ ដូច្នេះមិនមានភាពចាំបាច់ធ្វើនីតិវិធីទទួលស្គាល់ជាផ្លូវការចំពោះលោកមេធាវី RIVET នាពេលនេះទេ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| លេខ E3 | លេខកសចស | ERN | ចំណងជើង | ចំណាត់ថ្នាក់ | សម្គាល់ជាភាសាខ្មែរ | សម្គាល់ជាភាសាអង់គ្លេស | សម្គាល់ជាភាសាបារាំង |
|---|---|---|---|---|---|---|---|
| E3/1195 | D366/7.1.785 | 00057296-00057296<br>00519519-00519519<br>00531088-00531088 | ជូនមិត្ត Pang ជាទីស្រលាញ់និងនឹករលឹក | P | | | |
| E3/877 | 21.17 | 00021513-00021513<br>00185226-00185226<br>00283109-00283109 | ទូរលេខលេខ ៥៤ ជូនម.៨៧០ ជាទីគោរពស្នេហានឹករលឹក: មុខព្រួញ ដាក់ដាំកំទិចយួនស្លាប់ម្នាក់នៅថ្ងៃទី ២៥-០៥-១៩៧៧ | P | | | |
| E3/2594 | D175/3.41 | 00230459-00230598<br>00772315-00772319,<br>00766871-00766872<br>00773987-00773988 | ចម្លើយសារភាពរបស់ ម៉ែន ម៉េង ហៅ ឈិន | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1855 | 5.49 | 00015274-00015543<br>00795971-00795990,<br>00183295-00183295<br>00779528-00779548 | ចំលើយសារភាពរបស់ម៉ែន ម៉េងហៅឈិនជាភាសាខ្មែរ | P | | | |
| E3/2131 | 7.3 | 00006731-00006743<br>00182876-00182891<br>00842819-00842831 | បញ្ជីឈ្មោះអ្នកទោសផ្នែកកងពល កំទេចថ្ងៃទី ១០ មិថុនា ៧៧ | P | | | |
| E3/2592 | D175/3.30 | 00230380-00230385 | បញ្ជីឈ្មោះអ្នកទោសផ្នែក កងពល ៣១០ ចូលពីថ្ងៃទី ៩-៣០ មិថុនា ៧៧ | P | | | |
| E3/1204 | D366/7.1.800 | 00020855-00020855<br>00590303-00590303<br>00531056-00531056 | ទូរលេខ៣៨: គោរពជូនម.៨៧០ ជាទីគោរពស្នេហា | P | 00020855 | 00590303 | 00531056 |
| E3/58 | D125/160 | 00239934-00239940<br>00250086-00250092<br>00283912-00283918 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន វ៉ាន់ PHAN Van, Alias KHĂM Phăn | P | 00239936 | 00250088 | 00283914 |
| E3/447 | D369/4 | 00483241-00483252<br>00486510-00486520<br>00490547-00490558 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី PHAN Van ផាន វ៉ាន | P | | | |
| E3/1896 | 5.95 | 00077192-00077436,<br>00184466-00184482<br>00282400-00282464,<br>00769882-00769907<br>00761025-00761046 | ចម្លើយសារភាពរបស់ស៊ិនផល្គុន ហៅស៊ូជាភាសាខ្មែរ ចុះថ្ងៃទី១៣មិនា១៩៧៨ | P | | | |
| E3/1535 | 16.80 | 00021088-00021089<br>00183657-00183662 | ឈ្មោះអ្នកទោសផ្នែក ពេទ្យអង្គការ | P | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/3976 | D199/15 | 00349104-00349122 00346929-00346937 00342178-00342185 | កំណត់ហេតុនៃការស្តាប់ចម្លើយ AFFONCO Denise | P | 00349113, 00349120, | 00346934, 00346932, 00346936, 00346931 | 00342181, 00342184, 00342180 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចមិនអនុញ្ញាតឱ្យភាគីណាមួយធ្វើការជំទាស់ទៅនឹងការសួរសំណួររបស់ចៅក្រម។
- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យជនជាប់ចោទ នួន ជា (១២.០០) ចូលរួមដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួន។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូន សាក្សី ផាន វ៉ាន ហៅ ខាំ ផាន់ (TCW-307) ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំសាក្សី ផាន វ៉ាន ត្រឡប់មកកាន់សាលសវនាការវិញនៅព្រឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២។
- បង្គាប់ឱ្យមន្ត្រីតុលាការ អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ និងផ្នែកសោតទស្សន៍ សម្របសម្រួលរៀបចំផ្នែកបច្ចេកទេសដើម្បីស្តាប់សក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណី AFFONCO Denise បន្តនៅថ្ងៃទី ១៣ ធ្នូ ២០១២។
- បង្គាប់ដើមបណ្តឹងរដ្ឋប្បវេណី AFFONCO Denise (TCW-01) ត្រឡប់ទៅកាន់ទីកន្លែងផ្តល់សក្ខីកម្មដដែល សម្រាប់ការផ្តល់សក្ខីកម្មវេលារសៀលថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ខៀវ សំផន និង អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ (ចំពោះជនជាប់ចោទ អៀង សារី ត្រូវនាំមកកាន់បន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) ។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បតិ៍ ទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១២

ក្រឡាបញ្ជី

**ជាទ** [illegible] Matteo CRIPPA